# ពូជសណ្ដែកបាយ "CMB 01 "



ពូជសណ្ដែកបាយ ស៊ីអឹមប៊ី០១ " CMB01 " ត្រូវបានបញ្ចេញដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (កាឌី)នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាដើមឆ្នាំ ២០០៩ បន្ទាប់ពីបានធ្វើការពិសោធន៍អស់រយៈពេលប្រាំបីរដូវ (បួនឆ្នាំ) ចាប់ពីឆ្នាំ ២០០៥ កន្លងមក តាមរយៈថវិកាគម្រោង CARF និងកាឌី។ ពូជនេះមានប្រភពដើមចេញពីស្រទ្បាយ VC4152 របស់មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍ដំណាំបន្លែអាស៊ី (AVRDC) ដែលស្ថិតនៅកោះតៃវ៉ាន់។

## លក្ខណៈពិសេសៗរបស់ពូជសណ្ដែកបាយ "ស៊ីអឹមប៊ី ០១

"សណ្ដែកបាយ "ស៊ីអឹមប៊ី០១" ចេញផ្ការយៈពេល ៣៥ ថ្ងៃ និងទុំប្រមូលផលលើកទីមួយរយៈពេល ៦០ ថ្ងៃ បន្ទាប់ពីដាំ។ ដើមដងមានពណ៌បៃតង រាងជ្រុងឈរត្រង់ កម្ពស់ដើមប្រែប្រួលពី ៤៣-៦៧ ស.ម បែកមែកពី ២-៤ មែក។ នៅលើដើម និងមែកមានរោមតូចៗឆ្មារ។ ប្រព័ន្ធឫស មានឫសកែវ និងឫសរយោងដែលអាចចាក់ចូលទៅក្នុងដីជម្រៅ ពី ៥០-៦០ ស.ម ប៉ុន្តែ ៨០ ភាគរយនៃប្រព័ន្ធឫសស្ថិតនៅជម្រៅពី ៥-២០ ស.ម។ នៅលើឫសមានកំពកឫសតូចៗ បង្កើតឡើងដោយវត្តមាននៃបាក់តេរីមួយចំនួនក្នុងពួករីហ្សូប្យូម ដែលមានសមត្ថភាពស្រូប និងភ្ជាប់អាសូត (N) សេរីពីបរិយាកាស និងក្នុងដី។ ទម្រង់ស្លឹកមានលក្ខណៈពិសេស ងាយរលួយនៅក្នុងដីដែលជាប្រភពជីធម្មជាតិដ៏ប្រសើរសម្រាប់ដំណាំផ្សេងៗទៀត។ ផ្កាជាកញ្ចុំ ពេលរីកមានពណ៌លឿង ផ្លែមានរាងជាស៊ីឡាំងមូលទ្រវែង ផ្លែខ្ចីមានពណ៌បៃតងចាស់ និងផ្លែទុំមានពណ៌ខ្មៅ។ គ្រាប់មានពណ៌បៃតងប្រផេះ ចំនួនផ្លែក្នុង ១ ដើមពី ១០-១៩ ផ្លែ។ ចំនួនគ្រាប់ក្នុងមួយផ្លែពី ៧-១៣ គ្រាប់ ទម្ងន់ ១០០០ គ្រាប់ស្មើនឹង ៧០ ក្រាម និងទិន្នផលជាមធ្យម ៨៥២ គីឡូក្រាមក្នុងមួយហិកតា និងមានសក្តានុពលទិន្នផល ២,៣ តោនក្នុងមួយហិកតា។

## វិធីសាស្ត្រដាំដុះ

ពូជសណ្ដែកបាយ " ស៊ីអឹមប៊ី០១" អាចធ្វើការដាំដុះបានពេញមួយឆ្នាំដោយការបុកដាំជាជួរ ឬដាំតាមចង្អូរ និងដាំដោយព្រោះគ្រាប់ទៅលើដីដែលភ្ជួររួច ហើយរាស់លប់។ ចំពោះការដាំដោយបុកដាំជាជួរគួរប្រើគម្លាតគុម្ព ២៥-៣០ គុណនឹង ៣៥-៤០ ស.ម និងជម្រៅពី ២-៣ ស.ម ដោយក្នុងមួយរណ្ដៅដាក់គ្រាប់ចំនួន ៣-៤ គ្រាប់។ ការដាំដុះពូជសណ្ដែកបាយ "ស៊ីអឹមប៊ី០១" លើផ្ទៃដីមួយហិកតា គឺបើដាំដោយបុកដាំជាជួរត្រូវការគ្រាប់ពូជពី១៥-២០ គ.ក្រ/ហ.ត និងបើដាំដោយព្រោះត្រូវការគ្រាប់ពូជពី ៣០-៤០ គ.ក្រ/ហ.ត។

ក្រោយពីដាំបាន ១០-១៥ ថ្ងៃ គួរកាត់រំលោះកូនដោយទុកតែដើមណាដែលថ្លោស និងរឹងមាំល្អជាងគេចំនួន ១-២ ដើមក្នុងមួយគុម្ព និងត្រូវដកស្មៅចង្រៃឲ្យបានស្អាត ចៀសវាងការដណ្ដើមជីជាតិពីដំណាំដែលនាំឲ្យដំណាំដុះលូតលាស់យឺត។





## ការដុះលូតលាស់

ការធ្វើដីបានផុសល្អ ដីមានជីជាតិសំណើមគ្រប់គ្រាន់ និងធាតុអាកាសអំណោយផល ក្រោយពីដាំបាន ៣ ថ្ងៃ គ្រាប់ចាប់ផ្ដើមដុះទូលដីមកខាងលើ។ ចាប់ពីពេលដុះពន្លករហូតដល់អាយុ ១៥ ថ្ងៃ សណ្ដែកមានការដុះលូតលាស់ពុំសូវលឿនប៉ុន្មានទេ តែអាយុកាលចាប់ពី ២០ ថ្ងៃឡើងទៅ សណ្ដែកបាយមានការដុះលូតលាស់យ៉ាងលឿន។

## ការប្រើប្រាស់ជី

ការប្រើប្រាស់ជីតាមបច្ចេកទេស និងត្រឹមត្រូវតាមពេលវេលា ធ្វើឲ្យដំណាំដុះលូតលាស់ល្អទទួលបានទិន្នផលខ្ពស់។ ជីដែលអាចប្រើប្រាស់គឺជីអ៊ុយរ៉េ ដេអាប៉េ និងប៉ូតាស្យូម។ ការប្រើប្រាស់ជីចែកចេញជាពីរដំណាក់កាល គឺជីដេអាប៉េ និងប៉ូតាស្យូម (១០០ ភាគរយ) ដាក់ទ្រាប់បាតមុនពេលដាំ។ ចំណែកជីអ៊ុយរ៉េនៅសល់ ប្រើសម្រាប់ដាក់បំប៉នមួយលើកទៀត ក្រោយពីដាំបាន ២០ ថ្ងៃ ដើម្បីជំរុញការលូតលាស់ និងការបង្កើតកំពកឫស។ ចំណែកឯដីខ្សាច់ ដូចជាក្រុមដីប្រទះឡាង និងដីព្រៃខ្មែរគេចាំបាច់ត្រូវប្រើជីជីអ៊ុយរ៉េ ក្នុងបរិមាណច្រើនដើម្បីឲ្យដំណាំលូតលាស់ល្អ និងបង្កើនកំពកឫស។ ជីត្រូវដាក់ឃ្លាតពីគល់ ៥-១០ ស.ម រួចពូនដីលប់ឲ្យជិតដើម្បីទប់គល់ដំណាំផង និងការពារជីមិនឲ្យបាត់បង់តាមរយៈការហើរទៅក្នុងបរិយាកាស និងការហូរច្រោះដោយសារទឹកផង។ ចំពោះជីលាមកគោ ឬកំប៉ុស្ដិ៍ កសិករអាចប្រើនៅពេលទ្រាប់បាតក្នុងកម្រិត ៥ ត/ហ.ត ឬ ០,៥ គ.ក្រ/ម២ បន្ថែមលើជីគីមី បើសិនជាដីរបស់គាត់ខ្វះសារធាតុសរីរាង្គ។

| ឈ្មោះជី | កម្រិតជីទៅតាមក្រុមដី (គ.ក្រ / ហ.ត) | | |
|---|---|---|---|
| | ព្រៃខ្មែរ ប្រទះឡាង (ដីខ្សាច់-ល្បាយខ្សាច់) | កំពង់សៀម ឡាបានសៀក ទួលសំរោង (ដីល្បាយឥដ្ឋ) | កៀនស្វាយ (ដីល្បាយ) |
| អ៊ុយរ៉េ | ១៤៥ | ១៥ | ១៣ |
| ដេអាប៉េ | ១៣០ | ១៥៧ | ១៣៣ |
| ប៉ូតាស្យូម | ៥០ | ៥៨ | ៦៧ |

## ការប្រមូលផល

ផ្លែសណ្ដែកទុំអាចប្រមូលផលនៅរយៈពេល ៣០ ថ្ងៃ ក្រោយចេញផ្កា (ចំនួនផ្លែលើសពី ៩០ ភាគរយ ចាប់ផ្ដើមប្រែពណ៌ពីបៃតងក្រម៉ៅទៅជាខ្មៅ)។ គេអាចប្រមូលផលបាន ២-៣ លើក ក្នុងមួយវដ្ដជីវិតរបស់វា។ គម្លាតពេលប្រមូលផលពីមួយលើកទៅមួយលើកមានរយៈពេល ៥-៧ ថ្ងៃ។ ប៉ុន្តែការប្រមូលផលលើកទីបី ពុំសូវទទួលបានទិន្នផលច្រើន ដូចលើកទីមួយ និងទីពីរទេ។ ការយឺតយ៉ាវក្នុងការប្រមូលផល ជាហេតុធ្វើឲ្យទិន្នផលមានការបាត់បង់ដោយសារផ្លែទុំប្រេះនាំឲ្យជ្រុះគ្រាប់នៅរដូវប្រាំង ឬគ្រាប់សណ្ដែកអាចដុះ នៅក្នុងផ្លែបើមានភ្លៀងធ្លាក់ជាប់យូរថ្ងៃនៅរដូវវស្សា។

## ការទុកដាក់ក្រោយប្រមូលផល

ជាមធ្យមសំណើមគ្រាប់ក្រោយពេលប្រមូលផលពី ១៥-១៨ ភាគរយ ដូច្នេះតម្រូវឲ្យយើងធ្វើការហាលសម្ងួតបន្ថែមទៀតដោយកម្ដៅថ្ងៃ។ ការយឺតយ៉ាវក្នុងការហាលសម្ងួតក្រោយពេលប្រមូលផល និងការទុកដាក់គ្រាប់មិនបានត្រឹមត្រូវ គឺងាយរងការបំផ្លាញពីពពួកសត្វល្អិតចង្រៃ ដូចជាខ្មូតជាដើម ដោយវាស៊ីចោះផ្នែកខាងក្នុងរបស់គ្រាប់ដែលធ្វើឲ្យមានការបាត់បង់ទាំងទិន្នផលគុណភាព និងតម្លៃ។

## ការរក្សាទុកគ្រាប់ពូជ

ពូជសណ្ដែកបាយ "ស៊ីអឹមប៊ី០១" ជាពូជដែលអាចរក្សាទុកគ្រាប់ពូជដាំបានទៀតពី ២-៣ រដូវកាល ប្រសិនបើយើងធ្វើការបន្សុទ្ធពូជបានត្រឹមត្រូវ។ ការរក្សាទុកគ្រាប់ពូជសម្រាប់ប្រើប្រាស់នៅរដូវបន្ទាប់ គឺគ្រាប់ពូជត្រូវមានសំណើមពី ១២-១៣ ភាគរយ ហើយត្រូវរក្សាទុកនៅកន្លែងដែលគ្មានសត្វល្អិត គ្មានខ្យល់ចេញចូល ឬទុកនៅក្នុងធុងបិទជិត ឬអាចរក្សាទុកដោយប្រើប្រាស់ថ្នាំការពារសត្វល្អិត។